ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
****

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
យ.ក/លេខ ០៤២.០៨២/១៣គ.ជ.ប.អគ្គ.ពស

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៣

សន្និសីទសារព័ត៌មាន ស្តីពីការសរុបព្រឹត្តិការណ៍ទូទៅ នៃការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត

នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) វេលាម៉ោង ៦:០០ល្ងាច បានរៀបចំសន្និសីទសារព័ត៌មានមួយស្តីអំពី ការសរុបព្រឹត្តិការណ៍ទូទៅនៃការបោះឆ្នោតក្នុងថ្ងៃបោះឆ្នោត។

ឯកឧត្តម អ៊ុម សូស្ត ប្រធាន គ.ជ.ប បានមានប្រសាសន៍នៅក្នុងសន្និសីទនេះថា សម្រាប់ដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅទូទាំងប្រទេស មានការិយាល័យបោះឆ្នោតសរុបចំនួន ១៩,០០៩ ការិយាល័យ បានបើកព្រមៗគ្នាចាប់ពីម៉ោង ៧:០០ព្រឹក ហើយបញ្ចប់នៅម៉ោង ៣:០០ រសៀល ។ តាមខេត្តមួយចំនួនដូចជានៅខេត្តព្រះវិហារ ខេត្តប៉ៃលិន ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និងខេត្តបន្ទាយមានជ័យមានភ្លៀងរលឹមនៅតាមតំបន់ ចំណែកនៅឯខេត្តឧត្តរមានជ័យ និងខេត្តរតនគិរីមានភ្លៀងធ្លាក់ស្ទើរគ្រប់ទីកន្លែង ហើយនៅខេត្តមណ្ឌលគិរីក៏មានភ្លៀងធ្លាក់ខ្លាំងផងដែរ ប៉ុន្តែមិនបានបង្កឱ្យមានការអាក់ខានចំពោះដំណើរការបោះឆ្នោតនោះឡើយ ។

ឯកឧត្តមក៏បានលើកឡើងផងដែរថា នៅរាជធានី ខេត្តចំនួន៣ មានបញ្ហាកើតឡើងនៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត និងនៅការិយាល័យបោះឆ្នោតខ្លះ គឺនៅរាជធានីភ្នំពេញ ខេត្តព្រៃវែង និងខេត្តកណ្តាល បញ្ហាទាំងអស់នោះត្រូវបានដោះស្រាយតាមនីតិវិធី ។ ក្រោយពីបញ្ចប់ដំណើរការបោះឆ្នោតនៅវេលាម៉ោង ៣:០០ រសៀល ការិយាល័យបោះឆ្នោតបានបន្តដំណើរការរាប់សន្លឹកឆ្នោតជាធម្មតា ។

ឯកឧត្តម បានបញ្ជាក់ថា ចំពោះលទ្ធផលបឋមនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ នឹងប្រកាសនៅវេលាម៉ោង ៨:៣០នាទីយប់ តាមរយៈទូរទស្សន៍ជាតិកម្ពុជា ។